ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## លទ្ធផលជំនួបរវាង ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Chui Sai On នាយកប្រតិបត្តិនៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន

******

នៅរសៀលថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង១៦:០០ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបជាមួយ ឯកឧត្តម **Chui Sai On** នាយកប្រតិបត្តិនៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន ដែលនៅក្នុងឱកាសនោះ ថ្នាក់ដឹកនាំទាំងពីរបានរំលឹកពីទំនាក់ទំនងដ៏ជិតស្និទ្ធ និងជាមិត្តដែលមានជំនឿទុកចិត្តនឹងគ្នារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។ ទស្សនកិច្ចរបស់ឯកឧត្តម Chui Sai On ប្រព្រឹត្តទៅចំពេលដ៏ល្អប្រសើរនៃការប្រារព្ធខួបអនុស្សាវរីយ៍ ៦០ឆ្នាំ នៃទំនាក់ទំនងការទូត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន នឹងរួមចំណែកលើកកំពស់ទំនាក់ទំនងជាដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរ។

ឯកឧត្តម ប្រាក់ សុខុន និងឯកឧត្តម Chui Sai On បានវាយតំលៃខ្ពស់ចំពោះទស្សនកិច្ចនេះ ដែលនឹងជួយពង្រឹងពង្រីកទំនាក់ទំនង និងបង្កើនមិត្តភាពរវាងប្រជាជនកម្ពុជា និងចិន ក៏ដូចជារវាងប្រជាជនកម្ពុជា និងម៉ាកាវ។

ថ្នាក់ដឹកនាំទាំងពីរបានឯកភាពគ្នាចុះហត្ថលេខាលើ **អនុស្សារណៈយោគយល់គ្នារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន** ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីជម្រុញពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ ទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងរវាងយុវជន និងសហគមន៍ធុរកិច្ច ស្របតាមគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ។

តាមរយៈMOU ដែលបានចុះហត្ថលេខានេះ តំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា អាចនឹងរួមចំណែកយ៉ាងសំខាន់ដើម្បីបង្កើនវិនិយោគចិននៅកម្ពុជា ពិសេសលើវិស័យទេសចរណ៍ និងការធ្វើពាណិជ្ជកម្មកសិផលរបស់កម្ពុជា។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ភ្នំពេញ, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០១៨